# សេចក្ដីជូនដំណឹង

ក្រោយពីមានប្រតិកម្មពីលោក ហ៊ុន ម៉ាណែត
អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ
និងជាមេបញ្ជាការកងទ័ពជើងគោក
និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន
ទៅនឹងអត្ថបទដែល វីអូឌី បានចុះផ្សាយ
កាលពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៣
ពាក់ព័ន្ធនឹងការផ្ដល់ជំនួយដល់ប្រទេសតួកគី
ក្រុមការងារ វីអូឌី
នឹងដាក់លិខិតមួយច្បាប់ជូនប្រមុខរាជរដ្ឋាភិបាល
តាមរយៈខុទ្ទកាល័យ នៅថ្ងៃអាទិត្យនេះ។

VOD

មជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
Cambodian Center for Independent Media

លេខ៖.. ១៥០..................

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចនាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់**!

**វីអូឌី** ពិតជាមានការសោកស្តាយជាពន់ពេកចំពោះការផ្សព្វផ្សាយព័ត៌មានរបស់ វីអូឌី ដែលបានធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់ **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** និងរាជរដ្ឋាភិបាលដែលមានសម្តេចជាប្រមុខដឹកនាំ។

**វីអូឌី** សូមទោសសម្តេចផ្ទាល់ក៏ដូចជា **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** ចំពោះការផ្សាយអត្ថបទព័ត៌មាននោះ។

សូមសម្តេចនាយករដ្ឋមន្ត្រីមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

ថ្ងៃអាទិត្យ ៧រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៣
**នាយិកាស្តីទី**

**ឆន សុគន្ធា**

ផ្ទះលេខ១៤A ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ភ្នំពេញ, ទូរស័ព្ទលេខ៖ ០២៣ ៧២៦ ៨៤២ / ០២៣ ៧២៦ ៨៤៧ ទូរសារ៖ ០២៣ ៧២៦ ៨៤៥
House No14A Street 392, Sangkat Beoung Keng Kang I, Khan Chamkamon, Phnom Penh; Tel : 023 726 842 / 023 726 847 / 023 726 847 / 060 50 50 50;
Fax : 023 726 845, Hotline : 060 50 50 50 / 092 921 902 E-mail : info@ccimcambodia.org Website: www.ccimcambodia.org